ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

# តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៤៩
ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣
សាលដីកា
លេខ: ២១
ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៤

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៤
ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចខាងក្រោម:

១-ឯកឧត្តម [redacted] ជាប្រធាន
២-លោក [redacted] ជាចៅក្រម
៣-លោក [redacted] ជាចៅក្រម
៤-លោក [redacted] ជាចៅក្រម
៥-លោក [redacted] ជាចៅក្រម

ក្រឡាបញ្ជី

លោក [redacted]

តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៧២"ក្រIVច" ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ៤៩ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ របស់តុលាការកំពូល។

ពីបទ: មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន និងរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីខែមិថុនា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង ឲ្យផ្តន្ទាទោសតាមមាត្រា២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ និងមាត្រា៣៩១, ៣៩២ នៃក្រមព្រហ្មទណ្ឌ។

-ជនជាប់ចោទឈ្មោះ [redacted] រើសបៀត (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤៤ឆ្នាំ ជាតិខ្មែរឥស្លាម មុខរបរប្រធានក្រុមហ៊ុន កើតនិងទីលំនៅបច្ចុប្បន្ន [redacted] ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "ស" [redacted] ប្រពន្ធឈ្មោះ [redacted] មានកូន០៥នាក់ ទោសពីមុនធ្លាប់ជាប់ពន្ធនាគារម្តង។ ឃុំខ្លួនថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១២។



Scanned by CamScanner

-មានមេធាវីការពារលោក [redacted] ផាន់នី, [redacted] សុគន្ធ, [redacted] ដានី

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] វ៉ាវុឌ្ឍ (ជាចុងបណ្ដឹងសាទុក្ខ) ភេទប្រុស ទីលំនៅបច្ចុប្បន្ន [redacted]

-មានមេធាវីលោក [redacted] វិសាល

-កាលពីអំឡុងខែមិថុនា ឆ្នាំ២០០៩ ឈ្មោះ [redacted] អើសហ៊ើត ភេទប្រុស អាយុ៤៣ឆ្នាំ បាននិយាយល្បួងលោមឲ្យឈ្មោះ [redacted] វ៉ាវុឌ្ឍ ប្រគល់ប្រាក់ចំនួន៥៣.០០០$ (ប្រាំម៉ឺនបីពាន់ដុល្លារអាមេរិក) នៅពេលនោះឈ្មោះ [redacted] វ៉ាវុឌ្ឍ មានការជឿទុកចិត្តក៏ព្រមប្រគល់ប្រាក់ចំនួន ៥៣.០០០$ (ប្រាំម៉ឺនបីពាន់ដុល្លារអាមេរិក) ទៅឲ្យឈ្មោះ [redacted] អើសហ៊ើត ហើយឈ្មោះ [redacted] វ៉ាវុឌ្ឍ ប៉ុន្តែពេលឈ្មោះ [redacted] វ៉ាវុឌ្ឍ នេះបានសរសេរមូលប្បទានប័ត្រ ចំនួន០២សន្លឹក ឲ្យទៅឈ្មោះ [redacted] វ៉ាវុឌ្ឍ ប៉ុន្តែពេលឈ្មោះ [redacted] វ៉ាវុឌ្ឍ យកមូលប្បទានប័ត្រទៅបើកប្រាក់នៅធនាគារ ហើយធនាគារបញ្ជាក់ថា គ្មានទឹកប្រាក់ទេ។ បន្ទាប់មកនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ ឈ្មោះ [redacted] អើសហ៊ើត ក៏បានមកនិយាយល្បួងលោមឡានរថយន្តរបស់ឈ្មោះ [redacted] វ៉ាវុឌ្ឍ ម៉ាក Mercedes S៥០០ ផលិតឆ្នាំ២០០០ ដោយអះអាងថាយកទៅជិះអ្នកវិនិយោគដែលមករកស៊ីក្នុងប្រទេសកម្ពុជា ក្រោយពីបានរថយន្តហើយឈ្មោះ [redacted] អើសហ៊ើត បែរជាយករថយន្តទៅបញ្ចាំទៅវិញ ហើយបានប្រើល្បិចល្បួងលោមយកប្រាក់ពីឈ្មោះ [redacted] វ៉ាវុឌ្ឍ ជាបន្តបន្ទាប់ ដែលមានទឹកប្រាក់សរុបចំនួន១២៧.៥៦២.៥០$ (មួយសែនពីរម៉ឺនប្រាំពីរពាន់ ប្រាំរយហុកសិបពីរដុល្លារអាមេរិក និងហាសិបសេន) ទៀត។

-បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញថា: ប្ដឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេច:

-បញ្ជូនជនត្រូវចោទឈ្មោះ [redacted] អើសហ៊ើត ភេទប្រុស អាយុ៤៤ឆ្នាំ ទៅជំនុំជម្រះ។

-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ៣៨៨ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១២ និងជនត្រូវចោទព្រមទាំងវត្ថុតាងទៅចៅក្រមស៊ើបសួរ ដើម្បីចាត់ការតាមនីតិវិធីច្បាប់។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៤៩"ណ" ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេច:

១-ផ្ដន្ទាទោសឈ្មោះ [redacted] អើសហ៊ើត ភេទប្រុស អាយុ៤៤ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល០៣ឆ្នាំ (បីឆ្នាំ) ពីបទ: មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន និងរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីខែមិថុនា ឆ្នាំ២០០៩ និងក្នុងឆ្នាំ២០១១ តាមមាត្រា២៣១ នៃច្បាប់ស្ដីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ និងមាត្រា៣៩១, ៣៩២ នៃក្រមព្រហ្មទណ្ឌ។



Scanned by CamScanner

២-បង្គាប់ឱ្យឈ្មោះ [redacted] អើសហ្វ៊ើត ផ្ដល់សំណងថ្លៃចេញសែកថ្លៃយកប្រាក់ទៅលួសយករថយន្ត និងប្រាក់ជម្ងឺចិត្តសរុបចំនួន ៤០.០០០$ (បួនម៉ឺនដុល្លារអាមេរិក) ឱ្យទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភ័ន្តឡ ការទាមទារលើសពីនេះត្រូវច្រានចោល។

៣-វត្ថុចាប់យករួមមាន៖

១-ទូរស័ព្ទដៃចំនួន០២គ្រឿង ម៉ាកSamsung និងម៉ាកNokia។

២-សៀវភៅគ្រួសារលេខ១៧៧ ចំនួន១០ក្បាល។

៣-លិខិតឆ្លងដែនលេខ០៥៣៧០១៣ចំនួន០១ក្បាល។

៤-សៀវភៅធនាគារ Cambodia Public Bank លេខ០៩១២៨១ ចំនួន០១ក្បាល។

៥-សែកធនាគារកម្ពុជាសាធារណៈចំនួន០៣ក្បាល។

៦-លិខិតទិញលក់រថយន្ត០៣សន្លឹក។

៧-រថយន្តមួយគ្រឿងម៉ាក RAV៤ ពណ៌ទឹកមាស ពាក់ស្លាកលេខភ្នំពេញ ២A៨៥៥៨។

៨-សែកធនាគារកាណាឌីយ៉ា ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២ ដែលមានទឹកប្រាក់ចំនួន២៣០.០០០USD (ម្ភៃបីម៉ឺនដុល្លារអាមេរិក) ចំនួន០១សន្លឹក។

៩-សែកធនាគារ May Bank ចំនួន០៤សន្លឹក មួយសន្លឹកមានទឹកប្រាក់ចំនួន១៧០.០០០USD (ដប់ប្រាំពីរម៉ឺនដុល្លារអាមេរិក)។

១០-សែកធនាគារកម្ពុជាសាធារណៈ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលមានទឹក ប្រាក់ចំនួន ៨០.០០០USD (ប្រាំបីម៉ឺនដុល្លារអាមេរិក) ចំនួន០១សន្លឹក។ តាមកំណត់ហេតុទទួលវត្ថុតាង លេខ៩៤ អយធ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ត្រូវ ប្រគល់ឱ្យម្ចាស់ដើមវិញ។

៤-សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៨ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទ ចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី ចំពោះមុខមេធាវីការពារជនជាប់ចោទ និងមេធាវីការពារដើមបណ្ដឹងរដ្ឋប្បវេណី បើកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញបណ្ដឹងឧទ្ធរណ៍លេខ៤៨៩ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ភ័ន្តឡ ប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៤៩"ណ" ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល និងបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] អើសហ្វ៊ើត ប្ដឹងមិនសុខចិត្តនឹងសាលក្រម



Scanned by CamScanner

ព្រហ្មទណ្ឌលេខ៤៩"ណ" ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រប់ចំណុចទី១ និងទី២ នៃសេចក្តីសម្រេច។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថាៈ តម្កល់សាលក្រមលេខ៤៩"ណ" ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៧២"ក្រIVច" ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចៈ

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] អ៊ើសហ៊ើត ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២ របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] ភិរុន្ធ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៤៩"ណ" ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

៣-បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធីច្បាប់។

សាលដីកានេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី។

បើកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ២៧ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៣ របស់ឈ្មោះ អាប់ទុលឡាទីហ្វ អ៊ើសហ៊ើត ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៧២"ក្រIVច" ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ គ្រប់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញសារណាការពារចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] អ៊ើសហ៊ើត។

-បានឃើញសារណាចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] ភិរុន្ធ។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថាៈ

១-ទទួលបណ្តឹងសាទុក្ខលេខ២៧ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] អ៊ើសហ៊ើត ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធដោយខុសទៅនឹងគតិច្បាប់។



Scanned by CamScanner

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៧២IVច ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល។

សូមក្រុមប្រឹក្សាជំនុំជម្រះមេត្តា ពិនិត្យ និងសម្រេចតាមច្បាប់។

-បានស្តាប់សាវតាជាតិ និងចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ [redacted] អើសហ៊ៀត នាពេលសវនាការថា៖ គេចោទខ្ញុំថា ចេញសែកគ្មានប្រាក់ក្នុងរឿងនេះ ខ្ញុំមិនសុខចិត្តទេ ព្រោះខ្ញុំមិនបានប្រព្រឹត្ត។

កាលពីឆ្នាំ២០០៩ ខ្ញុំបានចេញមូលប្បទានប័ត្រ០២សន្លឹក ឲ្យទៅឈ្មោះ [redacted] វ៉ាវុឌ្ឍ គឺមានទឹកប្រាក់៣០០០ដុល្លារ និងមួយទៀត១៤០០ដុល្លារ ដោយពុំបានចុះថ្ងៃខែឆ្នាំ ក្នុងសែកនោះទេ។ សែកទាំង២សន្លឹកនេះមុនពេលឲ្យឈ្មោះ [redacted] វ៉ាវុឌ្ឍ ខ្ញុំបានប្រាប់គាត់ថា សែកនេះជារបស់ក្រុមហ៊ុន ទាល់តែមានសមាជិក៣នាក់ ចុះហត្ថលេខា ទើបអាចបើកបាន ពេលនោះឈ្មោះ [redacted] វ៉ាវុឌ្ឍ យល់ព្រមគាត់ និងយកសែកនេះទៅទុកហើយ ពេលណាមានប្រាក់សងគាត់វិញនោះ គាត់ប្រគល់សែក២សន្លឹកឲ្យខ្ញុំវិញ។

<u>សំណូមពរ:</u> លើកលែងទោសខ្ញុំ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីលោក [redacted] សុគន្ធ ការពារឲ្យជនជាប់ចោទឈ្មោះ [redacted] អើសហ៊ៀត នាពេលសវនាការថា៖ នៅក្នុងរឿងនេះ អំពីបញ្ហាចេញសែក២សន្លឹក ដែលមានទឹកប្រាក់៣០០០$ និងមួយទៀត១៤០០$ គឺជាសែកមិនមានលក្ខណៈត្រឹមត្រូវ ដោយពេលនោះកូនក្តីខ្ញុំមិនបានចុះហត្ថលេខា និងចុះថ្ងៃខែឆ្នាំ អំពីការបើកសែកនោះទេ ហើយទាល់តែមានសមាជិក៣នាក់ ចុះហត្ថលេខា ទើបអាចបើកបាន ហើយនៅក្នុងរឿងនេះឈ្មោះ [redacted] វ៉ាវុឌ្ឍ ក៏បានដឹងឮដែរ ម្យ៉ាងទៀតសែកនេះ មានរយៈពេល៣ឆ្នាំ មកហើយអស់សុពលភាពហើយ។

ពេលមានរឿងកើតឡើង បានឈ្មោះ [redacted] វ៉ាវុឌ្ឍ យកសែកនោះមកវិញ ប៉ុន្តែកូនក្តីខ្ញុំបានសងលុយអស់ហើយ។

បញ្ហារថយន្តនេះបានមកពីកំរៃជើងសារលក់ផ្លូវសេឡា ឲ្យក្រុមហ៊ុន ស៊ីន ទ្រី បាន២០០០០$ មិញពីលោក សុខ ហួត ដូចនេះរថយន្តនេះ គឺជាទ្រព្យសហកម្មសិទ្ធិ។

<u>សំណូមពរ:</u> សូមឲ្យកូនក្តីខ្ញុំរួចផុតពីបទចោទ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវី [redacted] វិសាល ការពារឲ្យដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] អើសហ៊ៀត និងកូនឈ្មោះ [redacted] វ៉ាវុឌ្ឍ នាពេលសវនាការថា៖ តាមអង្គហេតុឈ្មោះ [redacted] អើសហ៊ៀត បានខ្ចីលុយកូនក្តីខ្ញុំដោយចេញសែកឲ្យកូនក្តីខ្ញុំ ពេលកូនក្តីខ្ញុំទៅបើកលុយនៅធនាគារ សែកនោះគ្មានលុយទេ។ ក្តីខ្ញុំធ្លាប់រាប់អានគ្នា ក្រោយមកលោក [redacted] អើសហ៊ៀត បានខ្ចីលុយកូនក្តីខ្ញុំដោយចេញ

ចំពោះរថយន្តបើជាសហកម្មសិទ្ធិ ហេតុអ្វីបានជា [redacted] បកទៅបញ្ចាំហើយកូនក្តីខ្ញុំ ជាអ្នកយកលុយទៅលោស។

[redacted]ពីជាជនឆបោក ចេញសែកគ្មានលុយ ដើម្បីបោកប្រាស់កូនក្តីខ្ញុំយកលុយទៅលេងល្បែង។

<u>សំណូមពរ:</u> ផ្តន្ទាទោស[redacted] ទៅតាមច្បាប់។

សូមតម្កល់សាលដីកាសាលាឧទ្ធរណ៍ ទាំងមូល។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ និងសារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីគូក្តី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## <u>តុលាការកំពូល</u>

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] អើសហ៊ើត ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន។

-យល់ឃើញថា ការដែលសាលាដំបូងរាជធានីភ្នំពេញ និងសាលាឧទ្ធរណ៍សម្រេចផ្តន្ទាទោសលើឈ្មោះ [redacted] អើសហ៊ើត ដាក់ពន្ធនាគារកំណត់៣ឆ្នាំ ពីបទ: មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន និងរំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីខែមិថុនា ឆ្នាំ២០០៩ និងក្នុងឆ្នាំ២០១១ តាមមាត្រា២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ និងសមាត្រា៣៩១, ៣៩២ នៃក្រមព្រហ្មទណ្ឌ នោះជាការត្រឹមត្រូវហើយ ពីព្រោះថា:

ក-ជនជាប់ចោទបានចេញមូលប្បទានប័ត្រ ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីទៅបើកប្រាក់ពីធនាគារកម្ពុជាសាធារណៈ ចំនួន២ តែខាងធនាគារកម្ពុជាសាធារណៈ បានបញ្ជាក់តាមលិខិតចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១១ បញ្ជាក់ថា គ្មានទឹកប្រាក់ក្នុងគណនីទេ។ ដូច្នេះមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទពីបទ: មិនបំពេញកាតព្វកិច្ច ចំពោះឧបករណ៍អាចជួញដូរបាន មាត្រា២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិទូទាត់សងប្រាក់។

ខ-ចំពោះបទរំលោភលើសេចក្តីទុកចិត្ត អំពើរបស់ជនជាប់ចោទ ដែលបានយករថយន្តម៉ាកលិចសេស S៥០០ ផលិតឆ្នាំ២០១០ របស់ដើមបណ្តឹងរដ្ឋប្បវេណី ទៅបញ្ចាំដោយគ្មានការយល់ព្រមពីដើមបណ្តឹងរដ្ឋប្បវេណីនោះ ជាអំពើរំលោភលើសេចក្តីទុកចិត្ត។

-យល់ឃើញថា ការសម្រេចសេចក្ដីរបស់សាលាដំបូងរាជធានីភ្នំពេញ និងសាលាឧទ្ធរណ៍ ដែលបង្គាប់ឲ្យឈ្មោះ [redacted] អើសហៀត ផ្ដល់សំណងថ្លៃចេញសែក, ថ្លៃយកប្រាក់ទៅលោះរថយន្ត និងប្រាក់ជម្ងឺចិត្តសរុប៤០.០០០$ នោះតុលាការទាំង២ថ្នាក់ ពុំបានយល់ឃើញបញ្ជាក់ឲ្យបានច្បាស់លាស់នូវសំអាង និងសំណងលើការទាមទារនីមួយៗទេ។ សាលាឧទ្ធរណ៍គប្បីមានការសម្រេចអំពីទឹកប្រាក់លើការទាមទារនីមួយៗ ឲ្យបានច្បាស់លាស់ ព្រមទាំងសំអាងហេតុផង។

-យល់ឃើញថា សាលដីកាសភាព្រហ្មទណ្ឌលេខ៧២“ក្រIVច” ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្ដីមកនេះ ត្រឹមត្រូវតាមគតិច្បាប់ខ្លះ ខុសខ្លះ។

ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដី

១-ទទួលផ្នែកខ្លះនៃបណ្ដឹងសាទុក្ខលេខ ២៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] អើសហៀត។

២-តម្កល់សាលដីកាសភាព្រហ្មទណ្ឌលេខ ៧២“ក្រIVច” ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ទុកជាបានការ លើកលែងតែចំណុចបង្គាប់ឲ្យជនជាប់ចោទ ផ្ដល់សំណងថ្លៃចេញសែក, ថ្លៃលោះរថយន្ត និងជម្ងឺចិត្តចំនួន៤០.០០០ដុល្លារអាមេរិក ត្រូវបដិសេធចោល។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ៤៩ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះជាថ្មីឡើងវិញ លើចំណុចសំណងរដ្ឋប្បវេណី។

៤-សាលដីកានេះ ជំនុំជម្រះនៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៤ និងប្រកាសជាសាធារណៈនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៤។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
|---|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] | [redacted] |

បានចម្លងចេញពីសាលដីកាដើមត្រឹមត្រូវហើយ។
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ០៣ ឆ្នាំ២០១៤
ក្រឡាបញ្ជី
ភីម

បានឃើញ
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ០៣ ឆ្នាំ២០១៤
ជ.ប្រធានតុលាការកំពូល
អនុប្រធាន
[redacted]



Scanned by CamScanner